ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅបណ្តុះបណ្តាលអំពីកម្មវិធីជាតិកំចាត់ ជម្ងឺដង្កូវព្រូន នៅប្រទេសកម្ពុជា



ឧបត្ថម្ភការបោះពុម្ពដោយ

ខែកញ្ញា ឆ្នាំ២០១៤

USAID ជំនួយពីពលរដ្ឋអាមេរិក

END NEGLECTED TROPICAL DISEASES IN ASIA

fhi360 THE SCIENCE OF IMPROVING LIVES

## អារម្ភកថា

ក្នុងគោលបំណងធ្វើវិមជ្ឈការលើការប្រយុទ្ធនឹងជំងឺដង្កូវព្រូនពោះវៀននៅប្រទេសកម្ពុជា ដល់មន្ត្រីសុខាភិបាលគ្រប់ជាន់ថ្នាក់ កម្មវិធីជាតិកំចាត់ជំងឺដង្កូវព្រូន នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ នៃក្រសួងសុខាភិបាល បានរៀបរៀង "សៀវភៅបណ្តុះបណ្តាលសំរាប់កម្មវិធីជាតិកំចាត់ជំងឺដង្កូវព្រូន" ដែលជាមាត្រដ្ឋានគំរូ ក្នុងការបណ្តុះបណ្តាលមន្ត្រីសុខាភិបាលឲ្យបានយល់ដឹង ប្រើប្រាស់ និងអនុវត្តការប្រយុទ្ធនឹងជំងឺដង្កូវព្រូនពោះវៀន នៅតាមមូលដ្ឋានរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពខ្ពស់។

ការចែករំលែក ចំណេះដឹង និងបទពិសោធន៍ដល់មន្ត្រីថ្នាក់មូលដ្ឋានគឺជាកត្តាសំខាន់ក្នុងការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព និងជោគជ័យ។ សៀវភៅបណ្តុះបណ្តាលសំរាប់កម្មវិធីជាតិកំចាត់ជំងឺដង្កូវព្រូននេះ រៀបរាប់ និងពន្យល់យ៉ាងលំអិតពី ចំណេះដឹងទូទៅទាក់ទងនឹងជំងឺដង្កូវព្រូនពោះវៀន (ខួបវិវត្តន៍នៃដង្កូវព្រូនពោះវៀននីមួយៗ រោគសញ្ញា ផលលំបាក វិធានការទប់ស្កាត់ ការព្យាបាល និងការគ្រប់គ្រងជំងឺ) និងការរៀបចំកិច្ចតែងការ និងសំភារៈឧបទ្ទេសសំរាប់បង្រៀន មុនពេលចាប់ដំណើរការវគ្គបណ្តុះបណ្តាលនីមួយៗ។

ក្នុងនាមប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ ខ្ញុំសូមកោតសរសើរដោយស្មោះអស់ពីចិត្តចំពោះមន្ត្រីពាក់ព័ន្ធទាំងអស់ ជាពិសេសលោកស្រីវេជ្ជបណ្ឌិត **មុត ស៊ីនួន** លោកវេជ្ជបណ្ឌិត **ជា ហ៊ុច** និងលោកបណ្ឌិត **ខៀវ ទីរៈ** ដែលបានខិតខំពុះពារឧបសគ្គ និងចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួន ក្នុងការរៀបរៀងចងក្រងសៀវភៅនេះឡើង។ ខ្ញុំសង្ឃឹមជឿជាក់ថា សៀវភៅបណ្តុះបណ្តាលសំរាប់កម្មវិធីជាតិកំចាត់ជំងឺដង្កូវព្រូននេះ នឹងបានយកទៅអនុវត្តនៅតាមមន្ទីរសុខាភិបាល និងស្រុកប្រតិបត្តិទូទាំងប្រទេស។

ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់
ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ

**វេជ្ជបណ្ឌិត ច មឹង ហួ**

# មាតិកា


**សេចក្តីផ្តើម** ..................... ៥

**ទិសដៅ** ..................... ៦

**ប្រធានបទ និងរយៈពេលបណ្តុះបណ្តាល** ..................... ៨

១. ទិសដៅនៃកម្មវិធីជាតិកំចាត់ជម្ងឺព្រូន និងគោលបំណងនៃវគ្គបណ្តុះបណ្តាល ......... ៩

២. ជំងឺបង្កដោយដង្កូវព្រូនដែលប្រទះឃើញញឹកញាប់នៅកម្ពុជា ..................... ១២

- ជំងឺបង្កដោយដង្កូវព្រូនចំលងតាមដី ( *Soil-Transmitted Helminthiasis* ) ..... ១៣
- ជំងឺបង្កដោយដង្កូវព្រូនស៊ីស្តូសូម៉ាមេគង្គ ( *Schistosomiasis mekongi* ) ..... ១៥
- ជំងឺបង្កដោយដង្កូវព្រូនថ្លើម ( *Opisthorchiasis viverini* ) ..................... ១៧
- ជំងឺបង្កដោយដង្កូវព្រូនអំបោះ ( *Lymphatic filariasis* ) ..................... ១៧

៣. មូលហេតុបណ្តាលអោយកើតព្រូន ..................... ១៩

៤. ការផ្តល់ថ្នាំទំលាក់ព្រូន Mebendazole/Albendazole ដល់ក្រុមគោលដៅ ........ ២១

៥. គោលនយោបាយថ្នាក់ជាតិនៃការផ្តល់ថ្នាំទំលាក់ព្រូនប្រភេទ Mebendazole/ Albendazole ដល់ក្រុមគោលដៅ ..................... ២៤

៦. តួនាទី និងភារៈកិច្ចរបស់វិស័យពាក់ព័ន្ធក្នុងការផ្តល់ថ្នាំទំលាក់ព្រូនដល់ក្រុមគោលដៅ ..................... ២៦

៧. ទំរង់បែបបទការកត់ត្រា និងបែបបទធ្វើរបាយការណ៍សំរាប់ប្រើប្រាស់ក្នុងកម្មវិធីផ្តល់ថ្នាំទំលាក់ព្រូន តាមលំដាប់ថ្នាក់ ..................... ៣១

៨. ទំរង់ប្រព័ន្ធតាមដានត្រួតពិនិត្យ និងអភិបាលនៅថ្នាក់ស្រុកប្រតិបត្តិ មណ្ឌលសុខភាព និងសហគមន៍ ..................... ៤២

# សេចក្តីផ្តើម

សៀវភៅវគ្គបណ្តុះបណ្តាលសំរាប់កម្មវិធីជាតិកំចាត់ជម្ងឺដង្កូវព្រូននេះ រៀបរៀងឡើងសំរាប់ប្រើប្រាស់នៅពេលបើកវគ្គបណ្តុះបណ្តាលជាផ្លូវការទាក់ទងទៅនឹងការគ្រប់គ្រង ការផ្តល់ព័ត៌មាន និងផ្តល់ការពន្យល់ជាទំរង់យ៉ាងសាមញ្ញ និងងាយយល់។ សៀវភៅនេះក៏ត្រូវបានចែកទុកជាជំនួយលើការងារពីព្រោះព័ត៌មានដែលមាននៅក្នុងសៀវភៅនេះ គឺមានភាពពេញលេញ និងគ្រប់គ្រាន់ទាំងអស់ដោយមានទាំងការបង្ហាញ និងការអនុវត្តន៍ផ្សេងៗដើម្បីកាត់បន្ថយការកត់ត្រានៅពេលបង្រៀន។

ប្រធានបទសៀវភៅវគ្គបណ្តុះបណ្តាលសំរាប់កម្មវិធីជាតិកំចាត់ជម្ងឺដង្កូវព្រូន គឺផ្តោតលើ “ការគ្រប់គ្រង និងទប់ស្កាត់ការចម្លងរាលដាលនៃជំងឺដង្កូវព្រូនតាមរយៈការផ្តល់ថ្នាំទំលាក់ព្រូន និងអប់រំសុខភាព”។ ដូច្នេះសៀវភៅនេះសំរាប់ប្រើប្រាស់ដោយមន្ត្រីផ្តល់សេវាសុខាភិបាលជាទូទៅដែលបំពេញការងារលើកម្មវិធីដង្កូវព្រូននេះនៅគ្រប់លំដាប់ថ្នាក់។

មុនពេលដំណើរការវគ្គបណ្តុះបណ្តាលនេះ អ្នកបង្រៀនត្រូវមានបទពិសោធន៍គ្រប់គ្រាន់ ស្តីពីកម្មវិធីជាតិកំចាត់ជំងឺព្រូននៅក្នុងប្រទេសកម្ពុជា និងផ្ទាំងរូបភាពក៏ដូចជាបទបង្ហាញដែលជាឧបករណ៍ជំនួយសម្រាប់ការអនុវត្តន៍វគ្គបណ្តុះបណ្តាលនេះ ដើម្បីឱ្យខ្លួនមានភាពកក់ក្តៅក្នុងការសម្រេចបាននូវភាពជោគជ័យ ពីការចង្អុលបង្ហាញជំងឺព្រូនមួយៗអោយបានត្រឹមត្រូវ។ គ្រូសម្របសម្រួលវគ្គក៏គួរតែមានចំណេះដឹងដ៏ល្អមួយអំពីខួបវិវត្តន៍នៃជំងឺដង្កូវព្រូននិមួយៗ ផលវិបាក វិធានការណ៍ទប់ស្កាត់ និងគោលការណ៍ព្យាបាលថ្នាក់ជាតិក្នុងការគ្រប់គ្រងជំងឺដង្កូវព្រូន។ នៅពេលដែលអ្នកមានអារម្មណ៍កក់ក្តៅ និងយល់ដឹងរាល់ប្រធានបទ ឬផ្ទាំងរូបភាពជាឧបករណ៍ជំនួយសម្រាប់ អនុវត្តការងារ និងយល់នូវគោលការណ៍ជាតិអំពីការគ្រប់គ្រងជំងឺព្រូនហើយ ចូរអានសៀវភៅនេះឱ្យចប់ម្តង ឬច្រើនដង មុនពេលចាប់ដំណើរការវគ្គបណ្តុះបណ្តាលនិមួយៗ។

ពិនិត្យមើលគោលបំណងនៃការសិក្សា និងសម្ភារឧបទេ្ទសសំរាប់បង្រៀនវគ្គនីមួយៗជាមុន។ ការកត់សំគាល់នូវកំហុស និងភាពលំបាកដែលគេសង្កេតឃើញឧស្សាហ៍កើតឡើងអំឡុងពេលអនុវត្តន៍ផ្ទាល់លើបទបង្ហាញសម្ភារឧបទេ្ទសក៏ត្រូវបានរាប់បញ្ចូល និងកត់ចំណាំផងដែរ។ អ្នកនឹងឃើញថា ការកត់សម្គាល់នេះមានសារសំខាន់ ក្នុងអំឡុងពេលរៀបចំ និងការបង្រៀនរបស់អ្នក។

រៀងរាល់វគ្គបណ្តុះបណ្តាលអ្នកត្រូវរៀបចំសម្ភារ និងបរិក្ខាដែលអ្នកត្រូវការសម្រាប់វគ្គបណ្តុះបណ្តាលដោយមាន តារាងបញ្ជីឯកសារសម្ភារៈច្បាស់លាស់។ ចូរប្រើប្រាស់សៀវភៅនេះជាមគ្គុទេសក៏សំរាប់វគ្គនីមួយៗក្នុង អំឡុងពេលបង្រៀន។ នៅពេលពិនិត្យរួចរាល់សព្វគ្រប់ ដូច្នេះអ្នកអាចចាប់ផ្តើមបានហើយ!

# ទិសដៅ

## នៅពេលរៀនចប់វគ្គបណ្តុះបណ្តាលនិមួយៗ សិក្ខាកាមនិមួយៗ មានសមត្ថភាព និងអាចៈ

1. បានយល់ដឹងអំពីជំងឺដង្កូវព្រូនគ្រប់ប្រភេទនៅក្នុងប្រទេសកម្ពុជា
2. បានយល់ដឹងពីរបៀបឆ្លងនៃជំងឺដង្កូវព្រូន និងផលប៉ះពាល់
3. បានស្គាល់ពីរោគសញ្ញារបស់ប្រភេទដង្កូវព្រូននិមួយៗ
4. ចេះធ្វើសំណើសុំថ្នាំទំលាក់ព្រូនសំរាប់ផ្តល់ដល់ក្រុមគោលដៅ
5. ចេះបំពេញទំរង់របាយការណ៍តាមប្រព័ន្ធរបាយការណ៍របស់ក្រសួងសុខាភិបាល
6. ចេះប្រើប្រាស់ព័ត៌មានដែលមាននៅក្នុងសៀវភៅនេះ ដើម្បីទៅបង្រៀនដល់មន្ត្រីសុខភាពសាធារណៈ ដែលពាក់ព័ន្ធដទៃទៀតអោយបានយល់ដឹង
7. ចេះយល់ដឹងពីការកំណត់រោគវិនិច្ឆ័យប្រភេទដង្កូវព្រូនតាមរយៈការពិនិត្យលាមក
8. អនុវត្តន៍ និងសហការបានជោគជ័យលើយុទ្ធនាការផ្តល់ថ្នាំទំលាក់ព្រូនលើប្រជាជនចំណុច
9. ធ្វើរបាយការណ៍ និងចេះលើកសំណើសុំសម្ភារចាំបាច់ផ្សេងៗ

## តើប្រធានបទនិមួយៗនឹងត្រូវបង្រៀនយ៉ាងដូចម្តេច ?

### អ្នកសម្របសម្រួលៈ

អ្នកសម្របសម្រួល គឺជាអ្នកធ្វើការជាមួយគ្រូបង្ហាត់ ដើម្បីអោយគ្រូបង្ហាត់អាចសំរេចគោលដៅដូចបានរៀបរាប់ខាងលើ។ គ្រូបង្ហាត់ត្រូវមានបទពិសោធន៍ជ្រៅជ្រះ លើការគ្រប់គ្រងកម្មវិធីកំចាត់ជម្ងឺដង្កូវព្រូនដើម្បីងាយស្រួលក្នុងការដោះស្រាយបញ្ហាផ្សេងៗ។ អ្នកសម្របសម្រួលជួយដឹកនាំការពិភាក្សា ព្រមទាំងផ្តល់ជំនួយជាទូទៅដល់សិក្ខាកាមដែលចូលរួមវគ្គសិក្សា។

### ការធ្វើបទបង្ហាញៈ

ការបង្ហាញពីខ្លឹមសារនៃមេរៀន ត្រូវតែអោយច្បាស់ និងត្រូវខ្លីនៅពេលបង្ហាញម្តងៗ។ រាល់ព័ត៌មានដែលបានបង្ហាញ ត្រូវតែមានសរសេរនៅក្នុងសៀវភៅបង្រៀននេះជាស្រេច ព្រោះអាចជួយអោយសិក្ខាកាម មានការកត់ត្រាតិចតួចបំផុត ហើយការបង្ហាញខ្លឹមសារមេរៀននេះនឹងត្រូវលាយឡំជាមួយការពន្យល់បំភ្លឺ។

### ការអនុវត្តន៍:

ការអនុវត្តន៍នឹងត្រូវធ្វើអោយបានច្រើនតាមដែលអាចធ្វើបានដើម្បីជួយសិក្ខាកាមបានទទួលនូវបទពិសោធលើការបំពេញទំរង់សំណើសុំថ្នាំព្យួនក៏ដូចជារបាយការណ៍ ជាពិសេសអ្នកមីក្រូទស្សន៍អាចកំណត់ប្រភេទពងព្រូនតាមរយៈការពិនិត្យលាមកអ្នកជំងឺ ដែលពេលនេះអ្នកសម្របសម្រួលត្រូវបំបែកជាក្រុមតូចៗ ៤-៥នាក់ ក្នុងមួយក្រុម ដើម្បីអោយមានភាពងាយស្រួលក្នុងការតាមដានលើសិក្ខាកាមម្នាក់ៗ និងមានឱកាសក្នុងការអនុវត្តន៍អោយបានច្រើន។

### ការពិភាក្សាជាក្រុមតូចៗ:

នៅក្នុងពេលនេះ អ្នកសម្របសម្រួលនឹងដឹកនាំការពិភាក្សាលើប្រធានបទណាមួយ។ សកម្មភាពនេះនឹងផ្តល់ឱកាសដ៏ប្រសើរដល់សិក្ខាកាមគ្រប់ៗគ្នា ក្នុងការផ្តល់នូវយោបល់និងអភិវឌ្ឍន៍នូវគំនិត និងអាចរៀនសូត្រពីគ្នាទៅវិញទៅមក។

## ការវាយតំលៃវគ្គបណ្តុះបណ្តាល

តាមរយៈកំរងសំណួរគ្រូបង្ហាត់សាកសួរសិក្ខាកាមថា តើវគ្គបណ្តុះបណ្តាលនេះបានជួយអ្នកអោយមានភាពរីកចំរើនឬទេ? ការវាយតំលៃនេះត្រូវធ្វើឡើងនៅពេលបញ្ចប់វគ្គបណ្តុះបណ្តាលនិមួយៗ ដើម្បីអោយបាយដឹងពីកំរិតនៃការយល់ដឹងរបស់សិក្ខាកាមដែលមកចូលរួមវគ្គ។ សិក្ខាកាមនិមួយៗ អាចសរសេរឈ្មោះលើកំរងសំនួរ ឬមិនដាក់ឈ្មោះស្រេចតែចិត្ត ប៉ុន្តែសិក្ខាកាមមានសិទ្ធិពេញទីក្នុងការសំណូមពរដល់គ្រូបង្ហាត់ និងអ្នកសម្របសម្រួល ឬក៏ផ្តល់យោបល់ទៅលើខ្លឹមសារនៃវគ្គ និងទីកន្លែងបណ្តុះបណ្តាលដើម្បីអោយមានល្អប្រសើរជាងមុន។

# ប្រធានបទ និងរយៈពេលបណ្តុះបណ្តាល

**វគ្គបណ្តុះបណ្តាលនេះមានរយៈពេល ៤ ថ្ងៃ ដែលមានប្រធានបទសំខាន់ដូចជាៈ**

1. ទិសដៅនៃកម្មវិធីជាតិកំចាត់ជម្ងឺព្រូន និងគោលបំណងនៃវគ្គបណ្តុះបណ្តាល ៣០នាទី
2. ជំងឺបង្កដោយដង្កូវព្រូនដែលប្រទះឃើញញឹកញាប់នៅកម្ពុជា
   - ជំងឺបង្កដោយដង្កូវព្រូនចំលងតាមដី ( Soil Transmitted Helminthiasis ) ២៤០នាទី
   - ជំងឺបង្កដោយដង្កូវព្រូនស៊ីស្តូសូម៉ាមេគង្គ ( Schistosomiasis mekongi) ១២០នាទី
   - ជំងឺបង្កដោយដង្កូវព្រូនថ្លើម ( Opisthorchiasis viverrini ) ១២០នាទី
   - ជំងឺបង្កដោយដង្កូវព្រូនអំបោះ ( Lymphatic filariasis ) ៦០នាទី
3. មូលហេតុបណ្តាលអោយកើតព្រូន ៦០នាទី
4. ការផ្តល់ថ្នាំទំលាក់ព្រូន ( Mebendazole/Albendazole ) ដល់ក្រុមគោលដៅនៅក្នុងប្រទេសកម្ពុជា ១២០នាទី
5. គោលនយោបាយថ្នាក់ជាតិនៃការផ្តល់ថ្នាំទំលាក់ព្រូនប្រភេទ Mebendazole/ Albendazole ដល់ក្រុមគោលដៅ ៩០នាទី
6. តួនាទី និងភារៈកិច្ចរបស់វិស័យពាក់ព័ន្ធក្នុងការផ្តល់ថ្នាំទំលាក់ព្រូនដល់ក្រុមគោលដៅ ១៥០នាទី
7. ទំរង់បែបបទការកត់ត្រា និងបែបបទធ្វើរបាយការណ៍សំរាប់ប្រើប្រាស់ក្នុងកម្មវិធីផ្តល់ថ្នាំទំលាក់ព្រូនតាមលំដាប់ថ្នាក់ ១២០នាទី
8. ទំរង់ប្រព័ន្ធតាមដានត្រួតពិនិត្យ និងអភិបាលនៅថ្នាក់ស្រុកប្រតិបត្តិ មណ្ឌលសុខភាព និងសហគមន៍ ៦០នាទី

| ប្រធានបទទី១<br>រយៈពេល ៣០នាទី | **ទិសដៅនៃកម្មវិធីជាតិកំចាត់ជម្ងឺព្រូន<br>និងគោលបំណងនៃវគ្គបណ្តុះបណ្តាល** |
|---|---|

**គោលដៅនៃការសិក្សា**

នៅពេលរៀនចប់មេរៀននេះ សិក្ខាកាមនឹងៈ

- យល់ច្បាស់ពីកម្មវិធីផ្តល់ថ្នាំទំលាក់ព្រូន
- យល់ច្បាស់ពីដៃគូពាក់ព័ន្ធនានាដែលចូលរួមសហការ
- ពង្រឹងការសហការជាមួយដៃគូពាក់ព័ន្ធនានា

## កម្មវិធីផ្តល់ថ្នាំទំលាក់ព្រូន

មូលហេតុចំបងមួយក្នុងចំណោមមូលហេតុជាច្រើន ដែលបណ្តាលអោយកុមារមានភាពស្លេកស្លាំងដោយខ្វះជាតិដែក គឺដោយសារសត្វប៉ារ៉ាស៊ីតក្នុងពោះវៀន ដែលធ្វើអោយកុមារបាត់បង់ឈាមជាបន្តបន្ទាប់ ហើយសុទ្ធតែជាមូលហេតុដែលធ្វើអោយប៉ះពាល់ដល់សមត្ថភាពលូតលាស់របស់កុមារដោយផ្ទាល់។

សន្និបាតសុខភាពពិភពលោកឆ្នាំ2001 បានបង្កើតទិសដៅយ៉ាងជាក់លាក់សម្រាប់ទប់ស្កាត់ការឆ្លងរាលដាលនៃជង្គឺព្រូនពោះវៀនដែលឆ្លងតាមដី។ ជាមួយនឹងការផ្សព្វផ្សាយចេញនូវគោលនយោបាយនេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានឯកភាពកំណត់ផ្តល់ថ្នាំទម្លាក់ព្រូនយ៉ាងទៀងទាត់ យ៉ាងហោចណាស់ឱ្យបាន៧៥% និងឡើងដល់១០០% ដល់ប្រជាជនគោលដៅ ពិសេសគឺកុមារ ហើយសំខាន់បំផុតគឺ កុមារក្នុងវ័យសិក្សាដែលយើងងាយស្រួលនឹងផ្តល់ថ្នាំឱ្យ តាមរយៈសាលាមត្តេយ្យ សាលាបឋមសិក្សា សាលាមធ្យមសិក្សាទូទាំងប្រទេស ដែលជាក្រុមងាយទទួលរងការកើតជង្គឺព្រូនជាងគេឱ្យបានតាមទិសដៅដែលបានកំណត់។ លើសពីនេះ លោកគ្រូ អ្នកគ្រូ ព្រមទាំងគរុសិស្ស និងគរុនិស្សិតនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូទាំងអស់ក៏នឹងទទួលបានការផ្តល់ថ្នាំទម្លាក់ជង្គឺព្រូននេះផងដែរ។

ដើម្បីឱ្យកម្មវិធីនេះបានសម្រេចនូវសមិទ្ធផលឈានដល់ទិសដៅ ក្រសួងសុខាភិបាលបានបង្កើតនូវកម្មវិធីផ្តល់ថ្នាំទម្លាក់ព្រូនដល់ប្រជាជនគោលដៅ តាមរយៈសេវាពិគ្រោះជំងឺនៅគ្រប់សេវាពិនិត្យសុខភាពសាធារណៈ តាមរយៈសាលាមត្តេយ្យ សាលាបឋមសិក្សា សាលាមធ្យមសិក្សា គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងការផ្តល់សេវាសុខភាពចុះតាមមូលដ្ឋានរួមមានការចុះចាក់ថ្នាំបង្ការ ការផ្តល់ថ្នាំជីវជាតិអា សេវាពន្យារកំណើត និងការផ្តល់ថ្នាំទម្លាក់ជង្គឺព្រូនចំពោះក្រុមគោលដៅដូចជា កុមារអាយុ ១២ខែ ដល់ ៥៩ខែ ស្ត្រីមានគភ៌ចាប់ពី ៤ខែ ដល់ ៩ខែ ស្ត្រីក្រោយពេលសម្រាល កុមារមិនបានចូលរៀនអាយុពី ៦ឆ្នាំ ដល់ ១៥ឆ្នាំ និងស្ត្រីស្ថិតក្នុងវ័យបន្តពូជអាយុពី ១៥ឆ្នាំ ដល់ ៤៩ឆ្នាំ។

បច្ចុប្បន្ននេះ កម្មវិធីផ្តល់ថ្នាំទម្លាក់ដង្កូវព្រូន បានបញ្ជ្រាបចូលទៅក្នុងប្រព័ន្ធសាលារៀន និងសហគមន៍រួចទៅហើយ រីឯសកម្មភាពការងារក៏បាន និងកំពុងអនុវត្តន៍ ក៏ប៉ុន្តែសកម្មភាពការងារនេះត្រូវពង្រឹង និងពង្រីកបន្ថែម បើទោះបីជានៅមានឧបសគ្គបន្តិចបន្តួចនៅក្នុងតំបន់មួយចំនួន។ ដូច្នេះកិច្ចសហការរវាងមណ្ឌលសុខភាព និងសាលារៀនត្រូវតែពង្រឹង ដើម្បីជួយដោះស្រាយរួមគ្នានូវរាល់ឧបសគ្គ និងបញ្ជាក់ឱ្យច្បាស់ពីភារៈកិច្ចទទួលខុសត្រូវរៀងៗខ្លួន និងកំណត់ថារាល់របាយការណ៍ប្រចាំខែត្រូវបានបញ្ចូលក្នុងប្រព័ន្ធព័ត៌មានសុខាភិបាល (HIS)។

សិក្ខាសាលានេះនឹងជួយបំពេញនូវរាល់ចន្លោះខ្វះខាតទាំងអស់ ដើម្បីជួយជំរុញ និងធ្វើអោយកម្មវិធីផ្តល់ថ្នាំទំលាក់ព្រូននៅតាមសាលារៀន និងតាមរយៈសេវាចុះមូលដ្ឋានបានល្អប្រសើរគ្រប់លំដាប់ថ្នាក់ទាំងអស់។

## ទិសដៅ

1. ជួយស្តារសុខភាពប្រជាជនគោលដៅដែលងាយរងគ្រោះអោយរួចផុតពីការឆ្លងនៃពពួកដង្កូវព្រូន
2. បង្កើនការយល់ដឹង ផ្នែកអនាម័យដល់សហគមន៍ ដើម្បីទប់ស្កាត់ការចំលងរាលដាលនៃជំងឺដង្កូវព្រូន តាមរយៈការអប់រំសុខភាព

## គោលបំណងនៃសិក្ខាសាលា

1. កំណត់ពីមុខងារ និងការទទួលខុសត្រូវផ្នែកសុខាភិបាល និងផ្នែកអប់រំ ដើម្បីធានាថាគ្រាប់ថ្នាំព្រូន (Mebendazole/Albendazole) ត្រូវបានផ្តល់ដល់កុមារក្នុងវ័យសិស្សាបានទៀងទាត់ ២ដងក្នុងមួយឆ្នាំ តាមកាលបរិច្ឆេទច្បាស់លាស់
2. កំណត់ពីនីតិវិធីនៃការធ្វើរបាយការណ៍ និងសំណើសុំថ្នាំព្រូន (Mebendazole/Albendazole) រវាងនាយកសាលា រោងចក្រ និងមណ្ឌលសុខភាព អោយទាន់ពេលវេលា និងមានប្រសិទ្ធិភាព
3. មណ្ឌលសុខភាពមានតួនាទីភារកិច្ច ផ្តល់ថ្នាំព្រូន និងប្រមូលរបាយការណ៍ ពីនាយកសាលា រោងចក្រ និងពីសេវាចុះមូលដ្ឋាន
4. ពង្រឹងការពិនិត្យតាមដាន និងការធ្វើរបាយការណ៍ស្តីពីការផ្តល់ថ្នាំទំលាក់ព្រូននៅតាមសាលារៀនរោងចក្រ ដោយសហការរវាងប្រព័ន្ធសុខាភិបាលគ្រប់ថ្នាក់ (ខេត្ត/រាជធានី ស្រុកប្រតិបត្តិ មណ្ឌលសុខភាព) និងប្រព័ន្ធអប់រំគ្រប់ថ្នាក់ (ខេត្ត/រាជធានី ក្រុង/ស្រុក/ខណ្ឌ និងសាលារៀន)
5. ពង្រឹងការដាក់បញ្ចូលទិន្នន័យថ្នាំទំលាក់ព្រូនប្រភេទ Mebendazole/Albendazole គ្រប់ក្រុមគោលដៅទាំងអស់ (កុមារអាយុពី ១២-៥៩ខែ សិស្សសាលា ស្ត្រីមានគភ៌ចាប់ពីត្រីមាសទី២ និងស្ត្រីក្រោយពេលសំរាល) ទៅក្នុងប្រព័ន្ធព័ត៌មាន

## លទ្ធផលរំពឹងទុក

1. ផ្នែកសុខាភិបាល ផ្នែកអប់រំ និងផ្នែករោងចក្រ នឹងព្រមព្រៀងលើមុខងារ និងការទទួលខុសត្រូវទៅតាមផ្នែករៀងៗខ្លួន ដោយត្រូវតែដោះស្រាយយ៉ាងណា ដើម្បីធានាថាគ្រាប់ថ្នាំព្រូន (Mebendazole/Albendazole ) នឹងអាចផ្តល់ដល់សិស្សានុសិស្ស និងស្រ្តីបំរើការក្នុងរោងចក្រអោយបានទៀងទាត់ ក្នុងមួយឆ្នាំ ២ដង

2. នីតិវិធីនៃការធ្វើរបាយការណ៍ សំណើសុំថ្នាំព្រូន (Mebendazole/Albendazole) និងការផ្គត់ផ្គង់ថ្នាំព្រូន និងដំណើរការបានល្អប្រសើរ ហើយការអនុវត្តន៍ សកម្មភាពការងារដោយនាយកសាលា រោងចក្រ និងមណ្ឌលសុខភាព ប្រព្រឹត្តទៅបានទាន់ពេលវេលាដោយពុំមានបញ្ហា

3. កិច្ចសហការ រវាងប្រធានមណ្ឌលសុខភាព នាយកសាលារៀន និងរោងចក្រ ក្នុងការអនុវត្តន៍ការផ្តល់ថ្នាំទំលាក់ព្រូនដល់សិស្សសាលា ២ដងក្នុងមួយឆ្នាំ នឹងប្រព្រឹត្តទៅបានយ៉ាងល្អប្រសើរ និងទាន់ពេលវេលា

4. ទិន្នន័យថ្នាំព្រូន (Mebendazole/Albendazole) ដែលបានផ្តល់អោយសិស្សតាមសាលារៀន និងប្រជាជនចំណុច នៅមណ្ឌលសុខភាព និងសហគមន៍បានធ្វើរបាយការណ៍ យ៉ាងត្រឹមត្រូវ ហើយធានាថាទិន្នន័យទាំងនេះនឹងត្រូវបញ្ចូលទៅក្នុងប្រព័ន្ធព័ត៌មាននៃក្រសួងសុខាភិបាល

ប្រធានបទទី២
រយៈពេល ៥៤០នាទី

## ជំងឺបង្កដោយដង្កូវព្រូនដែលប្រទះឃើញញឹកញាប់នៅកម្ពុជា

### គោលដៅនៃការសិក្សា

នៅពេលរៀនចប់មេរៀននេះ សិក្ខាកាមនឹង៖

- យល់ច្បាស់ពីដង្កូវព្រូនដែលមាននៅក្នុងប្រទេសកម្ពុជា
- យល់ច្បាស់ពីតំបន់ចំលងខ្ពស់នៃជំងឺស៊ីស្តូ
- យល់ច្បាស់ពីតំបន់ចំលងខ្ពស់នៃជំងឺព្រូនអំបោះ
- យល់ដឹងពីកត្តាចំលង និងប្រភពចំលងនៃដង្កូវព្រូនគ្រប់ប្រភេទ
- យល់ដឹងពីវដ្តនៃការចំលងដង្កូវព្រូនគ្រប់ប្រភេទក្នុងខ្លួនមនុស្ស
- យល់ដឹងពីវដ្តនៃការចំលងដង្កូវព្រូនគ្រប់ប្រភេទក្នុងខ្លួនភ្នាក់ងារចំលង
- ពន្យល់បង្ហាញពីរបៀបឆ្លងនៃពពួកដង្កូវព្រូន
- ផលវិបាកនៃអ្នកកើតជំងឺស៊ីស្តូ និងព្រូនអំបោះប្រសិនបើគ្មានការព្យាបាលទាន់ពេលវេលា

### ដង្កូវព្រូន

ព្រូន គឺជាពពួកប៉ារ៉ាស៊ីតចង្រៃម៉្យាងដែលអាចមាននៅក្នុងរាងកាយរបស់មនុស្ស សត្វ ហើយដែលរស់នៅដោយបឺតស្រូបយកជីវជាតិពីមនុស្សឬសត្វដើម្បីចិញ្ចឹមជីវិត។ តើហេតុអ្វីបានជាពួកវាចូលក្នុងរាងកាយមនុស្សយើង ដោយយើងមិនបានដឹងសោះ? ព្រូនខ្លះអាចមើលឃើញនៅពេលវាចេញមកក្រៅតាមលាមកជួនកាលព្រូនអាចចេញមកក្រៅតាមមាត់។ ព្រូនខ្លះតូចៗណាស់យើងមិនអាចមើលឃើញវាទេ តែយើងអាចមើលវាឃើញតាមរយៈការពិនិត្យលាមកដោយឧបករណ៍មីក្រូទស្សន៍។

គ្រូសម្របសម្រួលវគ្គបណ្តុះបណ្តាល ធ្វើបទបង្ហាញអំពីប្រភេទដង្កូវព្រូន ដែលកម្មវិធីជាតិបានសិក្សាស្រាវជ្រាវឃើញនៅក្នុងប្រទេសកម្ពុជាដោយបញ្ជាក់ពីភាពប៉ះពាល់ដល់បញ្ហាសុខភាពជាសាធារណៈ ដល់ប្រជាពលរដ្ឋមានជាអាទិ៍៖

## 1. ជង្គូវព្រូនចំលងតាមដី ( *Soils-Transmitted Helminth* )

### ក. ព្រូនចង្អឹះ ( *Ascaris lumbricodes* )

- ពន្យល់ពីការចំលងរោគ
- កត្តាបង្កអោយមានការចំលង
- ប្រភពចំលង
- អំពីវដ្តនៃការចំលងជំងឺព្រូនចង្អឹះ
- ទីតាំងជង្គូវព្រូននៅក្នុងខ្លួនមនុស្ស សត្វ
- ការវិវត្តន៍ពងព្រូនចង្អឹះនៅនឹងបរិស្ថាន ( ដី )
- ផលវិបាកនៃការផ្ទុកព្រូនចង្អឹះ




### ខ. ព្រូនរំពាត់សេះ ( *Trichuris trichiura* )

- ពន្យល់ពីការចំលងរោគ
- កត្តាបង្កអោយមានការចំលង
- ប្រភពចំលង
- អំពីវដ្តនៃការចំលងជំងឺព្រូនចង្អឹះ
- ទីតាំងជង្គូវព្រូននៅក្នុងខ្លួនមនុស្ស សត្វ
- ផលវិបាកនៃការផ្ទុកព្រូនចង្អឹះ




### គ. ជង្គូវព្រូនអៀន ( *Enterobius vermicuralis* )

- ពន្យល់ពីការងាយចំលងនៃព្រូនអៀន
- កត្តាបង្កអោយមានការចំលង
- ប្រភពចំលង និង ការចំលងដោយខ្លួនឯង
- អំពីវដ្តនៃការចំលងជំងឺព្រូនអៀន
- ទីតាំងជង្គូវព្រូនអៀននៅក្នុងខ្លួនមនុស្ស
- ការវិវត្តន៍ពងព្រូនអៀន
- ផលវិបាកនៃការផ្ទុកព្រូនអៀន



ពងព្រូនអៀនដែលពិនិត្យឃើញលើកុមារមត្តេយ្យនៅប្រទេសកម្ពុជា



### ឃ. ព្រូនទំពក់ ( *Hookworms* )




- ពន្យល់ពីការចំលងរោគ
- កត្តាបង្កអោយមានការចំលង
- ប្រភពចំលង
- អំពីវដ្តនៃការចំលងជំងឺព្រូនចង្កឹះ
- ទីតាំងដង្កូវព្រូននៅក្នុងខ្លួនមនុស្ស សត្វ
- ផលវិបាកនៃការផ្ទុកព្រូនទំពក់

### ង. ដង្កូវព្រូនអង្គីលីល ឬព្រូនសសៃ ( *Strongyloide stercoralis* )

- ពន្យល់ពីការចំលងដង្កូវព្រូនអង្គីលីល
- ភាពស៊ាំញុាំនៃការចំលងដង្កូវព្រូនសសៃ
- ប្រភពចំលង និងការចំលងដោយខ្លួនឯង
- អំពីវដ្តនៃការចំលងជំងឺដង្កូវព្រូនសសៃ
- ទីតាំងដង្កូវព្រូនសសៃនៅក្នុងខ្លួនមនុស្ស សត្វ
- ការវិវត្តន៍នៃកូនដង្កូវព្រូនសសៃនៅនឹងដី
- ផលវិបាកនៃការផ្ទុកព្រូនសសៃ



### ព័ត៌មានអេពីដេមីសាស្ត្ររបស់ព្រូនជំងឺព្រូនអង្គីលីលឬព្រូនសសៃនៅប្រទេសកម្ពុជា

អត្រាប្រេវ៉ាឡង់នៃជំងឺព្រូនអង្គីលីល ឬព្រូនសសៃតាមក្រុមអាយុលើប្រជាជន២៣៩៦នាក់ នៅក្នុងខេត្តព្រះវិហារនាឆ្នាំ២០១០។ លទ្ធផលបានបញ្ជាក់ថាទាំងកុមារ និងមនុស្សធំ អត្រាកើតជំងឺនេះ គឺមានអត្រាប្រហាក់ប្រហែលគ្នាគឺ >40%។




### 2. ជំងឺស៊ីស្តូសូមីញ៉ាស៊ីសមេគង្គ ( *Schistosoma mekongi* )

គ្រូឧទ្ទេសនាមរៀបរាប់ពន្យល់ពីជម្ងឺស៊ីស្តូមេគង្គ ដែលមាននៅក្នុងប្រទេស និងពីបញ្ហាចំពោះមុខ។ ជំងឺស៊ីស្តូកើតមាននៅក្នុងខេត្តស្ថិតនៅតាមទន្លេមេគង្គតែ២ប៉ុណ្ណោះគឺខេត្តក្រចេះ (ស្រុកសំបូរ និងស្រុកក្រចេះ) និងខេត្តស្ទឹងត្រែង (ស្រុកសៀមបូក ថាឡាបរិវ៉ាត់ សេសាន និងសេកុង)។

ជំងឺស៊ីស្តូមានកើតតែនៅតំបន់តាមដងទន្លេមេគង្គនៃខេត្តស្ទឹងត្រែងនិងក្រចេះក្នុងប្រទេសកម្ពុជាដែលជាកន្លែងមានល័ក្ខខ័ណ្ឌអេកូសាស្ត្រអំណោយផលសម្រាប់ការចំលងជំងឺ។ នៅប្រទេសកម្ពុជាជំងឺនេះបង្កឡើងដោយព្រូនស៊ីស្តូសូម៉ាមេគង្គ ( *Schistosoma mekongi* ) ហើយភ្នាក់ងារចម្លង គឺប្រភេទខ្យង *Neotricuta aperta* ( ខ្យងខ្លា ) ដែលទំ និងរស់នៅក្នុងប្រហោងថ្មក្នុងទន្លេមេគង្គ នៅពេលទឹកស្រក ថ្មនោះលេចចេញពីទឹកពាក់កណ្តាល។ សត្វចតុបាទ ជាពិសេសសត្វឆ្កែក៏ទទួលរងការចំលងជំងឺស៊ីស្តូដែរ វាក៏ជាអ្នកផ្ទុកភ្នាក់ងារចំលងដ៏សំខាន់ក្នុងការចម្លងបន្ត។ ចំនួនប្រជាជន ដែលប្រឈមមុខនឹងការឆ្លងត្រូវបានគេប៉ាន់ស្មានថាជាង ៨ម៉ឺននាក់។ មុនពេលដែលវិធានការគ្រប់គ្រងជំងឺនេះត្រូវបានបង្កើតឡើង អត្រាប្រេវ៉ាឡង់នៃអ្នកកើតជំងឺស៊ីស្តូ នៅតំបន់ចម្លងខ្ពស់នៃជំងឺនេះ គឺមានរហូតដល់ជាង ៧០% នៅក្នុងចំណោមកុមារសិស្សសាលា និង៤៩%ចំពោះប្រជាជនទូទៅ។ ការចម្លងនៃជំងឺកើតមានឡើងនៅរដូវទឹកសម្រក នាចុងរដូវប្រាំង ចាប់ពីខែកុម្ភៈ ដល់មេសា ដែលពេលនោះ ទឹកទន្លេស្រករាក់ និងក្តៅឧណ្ហៗ។ មានកត្តាជាច្រើនដែលប្រឈមមុខចំពោះការចំលងនៃជំងឺ គឺសកម្មភាពប៉ះពាល់ផ្ទាល់នឹងទឹកទន្លេ

ដូចជាកុមារហៃលទឹកការបោកគក់របស់ស្ត្រី និងសកម្មភាពនេសាទ។ វិធានការណ៍គ្រប់គ្រងទប់ស្កាត់ការចំលងជំងឺរាប់ទាំងការព្យាបាលជាសមូហភាពដោយថ្នាំប្រាសុីកង់តែល (*Praziquantel*) ត្រូវបានអនុវត្ត ចាប់តាំងពីឆ្នាំ១៩៩៦មកម្លេះ។

## ពន្យល់សិក្ខាមអោយបានដឹងច្បាស់អំពី

- កត្តាបង្កអោយមានការចំលង
- ភ្នាក់ងារចំលងនៃជម្ងឺសុីស្តូ
- អំពីវដ្តនៃការចំលងជំងឺសុីស្តូលើមនុស្ស សត្វ
- ការវិវត្តន៍ពងព្រូនសុីស្តូក្នុងខ្យងខ្លា (ភ្នាក់ងារចម្លង)
- ផលវិបាកនៃការកើតជំងឺសុីស្តូ






ភ្នាក់ងារចម្លង៖ ខ្យងខ្លា (*Neotricuta aperta*)

អ្នកជំងឺសុីស្តូដែលមានផលវិបាកមុនអនុវត្តការព្យាបាលជាសមូហភាព (សិក្ខាកាមគួរតែត្រូវដឹងពីបញ្ហានេះ)



## ផែនការយុទ្ធសាស្រ្តសំរាប់គ្រប់គ្រងជំងឺសុីស្តូ

- យុទ្ធនាការផ្តល់ថ្នាំព្យាបាលជាសមូហភាពដល់ប្រជាជនរស់នៅតំបន់ប្រឈម
- សិក្សាស្រាវជ្រាវ និងតាមដានជាប្រចាំនៅតំបន់ចំលងខ្ពស់នៃជំងឺ (ពិនិត្យលាមកមនុស្ស និងសត្វដូចជា គោ ក្របី ឆ្កែ និងជ្រូក)
- សិក្សាស្រាវជ្រាវពីភ្នាក់ងារចំលង (ខ្យងខ្លា)
- អប់រំប្រជាជនក្នុងសហគមន៍អោយយល់ដឹងពីវិធានការណ៍ការពារ

## 3. ជំងឺព្រូនក្នុងថ្លើម ( *Opisthorchis viverrini* )

ក្នុងប្រទេសកម្ពុជា ជំងឺព្រូនក្នុងថ្លើមដែលបង្កដោយប្រភេទព្រូន *Opisthorchis viverrini* ភាគច្រើនកើតនៅលើប្រជាជនដែលមានទំលាប់ចូលចិត្តបរិភោគភ្លាត្រី ខ្យងឆៅ ឬចំអិនមិនបានឆ្អិនល្អ។ ទំលាប់នៃការបរិភោគម្ហូបអាហារឆៅមានជាទូទៅនៅច្រើនតំបន់ក្នុងប្រទេស។ តាមការស្រាវជ្រាវក្នុងពេលបច្ចុប្បន្ននេះ បានបង្ហាញអោយឃើញថា ប្រជាជនដែលកំពុងរស់នៅក្នុងស្រុកមួយចំនួនប៉ែកភូមិភាគទក្សិណ និងនិរតីនៃប្រទេស ជាពិសេស គឺបណ្តាខេត្តដែលមានព្រំប្រទល់ជាប់ជាមួយប្រទេសវៀតណាម និងឡាវដែលអត្រាអ្នកមានផ្ទុកជំងឺព្រូនក្នុងថ្លើម ដែលបង្កដោយប្រភេទព្រូន *Opisthorchis viverrini* ចន្លោះពី 1–54%។

### បង្ហាញ និងពន្យល់សិក្ខាមអំពី

- កត្តាបង្កអោយមានការចំលង
- អំពីវដ្តនៃការចំលងជំងឺព្រូនថ្លើមលើមនុស្ស សត្វ
- ការវិវត្តន៍ពងព្រូនថ្លើមក្នុងខ្យង (ភ្នាក់ងារចម្លងទី១)
- ការវិវត្តន៍កូនដង្កូវព្រូនថ្លើមក្នុងត្រី (ភ្នាក់ងារចម្លងទី២)




## 4. ជំងឺព្រូនអំបោះ ( *Lymphatic filariasis* )

ជំងឺព្រូនអំបោះ (LF) ជាជំងឺបង្កដោយដង្កូវ *Wucheraria bancrofti*។ នៅប្រទេសកម្ពុជាយើងជំងឺនេះកើត និងរាតត្បាតនៅក្នុងខេត្តចំនួន៤។ ប្រទេសកម្ពុជាបានធ្វើការជាមួយកម្មវិធីសកលដោយតាំងចិត្តលុបបំបាត់ជំងឺនេះអោយអស់ពីប្រទេសរបស់ខ្លួន។ ការគូសផែនទីបញ្ជាក់ពីតំបន់កើតជំងឺព្រូនអំបោះទូទាំងប្រទេសត្រូវបានធ្វើឡើង និងបញ្ចប់នៅក្នុងឆ្នាំ២០០៤។ មានស្រុកចំនួន១៨ នៅក្នុងខេត្ត៤ គឺខេត្តរតនគីរី (ស្រុកទាំង៩) ខេត្តស្ទឹងត្រែង (ស្រុកទាំង៥) ខេត្តព្រះវិហារ (ស្រុករវៀង) និងសៀមរាប (ស្រុក៣: ស្រុកសៀមរាប វ៉ារិន និងអង្គរជុំ) ត្រូវបានចាត់ទុកថាតំបន់ដែលកំពុងមានការចំលងជំងឺព្រូន។ ដោយមានផែនការយុទ្ធសាស្ត្រច្បាស់លាស់ក្នុងការលុបបំបាត់ជំងឺព្រូននេះដែលបានដំណើរការតាំងពីឆ្នាំ២០០៥មក កាលពីឆ្នាំ២០០៩នេះ កម្មវិធីជាតិបានសំរេចរួចរាល់ហើយ នូវការការព្យាបាលជាសមូហភាព (MDA) ជុំ ទី៥។

## ពន្យល់សិក្ខាមអំពី

- កត្តាបង្កអោយមានការចំលង
- អំពីវដ្តនៃការចំលងជំងឺព្រូនអំបោះ ក្នុងខ្លួនមនុស្ស
- ការវិវត្តន៍កូនដង្កូវព្រូនក្នុងខ្លួនមូស (ភ្នាក់ងារចម្លង)




## ស្ថានភាពជំងឺបច្ចុប្បន្ននៃជំងឺព្រូនអំបោះ

- បញ្ឈប់ការផ្តល់ថ្នាំព្យាបាលដោយសមូហភាពដល់ប្រជាជនដែលរស់នៅតំបន់ប្រឈមនឹងជំងឺ
- ពិនិត្យតាមដានដោយធ្វើការស្រាវជ្រាវលើកុមារអាយុពី ៦-៧ឆ្នាំ តាមរយៈការតេស្តរហ័សមើលអង់ទីហ្សែនក្រែងនៅមានការចំលងក្រោយពីការព្យាបាលដោយ ថ្នាំបាន ៥ជុំហើយ
- អប់រំប្រជាជននៅក្នុងសហគមន៍ស្តីពីវិធានការការពារ
- ពិនិត្យ ថែទាំអ្នកជំងឺដែលមានផលវិបាកនៃជំងឺរួចហើយ

ប្រធានបទទី៣
រយៈពេល ៦០នាទី

# មូលហេតុបណ្ដាលអោយកើតព្រូន

### គោលដៅនៃការសិក្សា

នៅពេលរៀនចប់មេរៀននេះ សិក្ខាកាមនឹង៖

- អាចពណ៌នាបានពីមូលហេតុបណ្ដាលឲ្យកើតព្រូន
- យល់ច្បាស់ពីរោគសញ្ញាពាក់ព័ន្ធនឹងការកើតព្រូន
- អាចពន្យល់បានពីផលវិបាកដែលបង្កដោយដង្កូវព្រូន
- អាចពន្យល់បង្ហាញបានពីក្បួនអនាម័យ

## មូលហេតុដែលបណ្ដាលអោយកើតព្រូន

ជំងឺព្រូនភាគច្រើនកើតមានឡើងបណ្ដាលមកពីការខ្វះការយល់ដឹង និងយកចិត្តទុកដាក់អំពីអនាម័យ កុមារជាច្រើនទំលាប់ជុះពាសវាលពាសកាលនៅក្បែរផ្ទះឬក្នុងគុម្ពោធព្រៃជិតៗផ្ទះ និងភូមិដែលខ្លួនរស់នៅ។ មូលហេតុផ្សេងៗទៀតដូចជា ការប្រើប្រាស់ទឹកមិនស្អាត ញាំទឹកឆៅ ញាំបន្លែ ឬផ្លែឈើមិនបានលាងសំអាតមុនពេលបរិភោគ និងទំលាប់បរិភោគត្រីសាច់ឬសាច់ចំអិនមិនបានឆ្អិនល្អ ដើរជើងទទេរ ដៃមិនស្អាតយកមកលូកមាត់ ឬចាប់កាន់អាហារញាំជាដើម។

បន្ថែមលើនេះទៀត សត្វរុយជាភ្នាក់ងារសំខាន់ក្នុងការចំលងមេរោគផ្សេងៗជាច្រើន។ រុយអាចទំលើលាមកសំរាមឬទំលើគំរង់ខ្មោចសត្វ ហើយរុយក៏ចូលចិត្តទំលើអាហាររបស់យើងដែរ។ នៅពេលរុយទំលើអាហារវានឹងបន្សល់ទុកមេរោគនៅលើចំណីអាហាររបស់អ្នកដែលបណ្ដាលអោយអ្នកកើតជំងឺ។ អ្នកអាចកើតជំងឺរាគរូស ក្អួតចង្អោរ ឈឺពោះ....ហើយកើតជំងឺព្រូននៅក្នុងពោះ។

## លក្ខណៈសំគាល់អ្នកកើតជំងឺព្រូន

ចំពោះកុមារ គឺមានរាងកាយស្លេកស្លាំង ឧស្សាហ៍ចុកពោះ រាគ ក្អួត ជួនកាលមានក្ដៅខ្លួន រមាស់គូថ កុមារញាំច្រើនតែមិនធំធាត់ អត់មានកំលាំង ស្រកទំងន់ ពេលគេងមានភាពរសាប់រសល់ គេងមិនសូវលក់ស្រួល ធំពោះ។

### ផលវិបាក

- ព្រូនវាជញ្ជក់យករសជាតិអាហារដែលកុមារបរិភោគ ជាហេតុធ្វើអោយកុមារមានជំងឺកង្វះអាហាររូបត្ថម្ភ បាត់បង់កំលាំងពលកម្ម ស្លេកស្លាំង ខ្សោយបញ្ញា ស្មារតី យឺតយ៉ាវក្នុងការរីកធំធាត់
- ព្រូនចង្អឹះ វាអាចចាក់ស្រេះមូលផ្តុំគ្នាច្រើន បណ្តាលអោយស្ទះពោះវៀន តំរូវអោយធ្វើការវះកាត់
- ព្រូនទំពក់វាភ្ជាប់ខ្លួនវាដោយថ្ពក់ទៅនឹងជញ្ជាំងពោះវៀន រួចវាបឺតឈាម បណ្តាលអោយមានជំងឺស្លេកស្លាំង រាគ មួលពោះ ធ្លាក់ត្រសាល់គូថ

### វិធីការពារទប់ស្កាត់ការឆ្លងរាលដាលនៃដង្កូវព្រូនពោះវៀន

កុមារទាំងឡាយត្រូវចងចាំអោយបានច្បាស់ អំពីក្បួនអនាម័យក្នុងការការពារជំងឺព្រូន ក៏ដូចជាការពារជំងឺ ឆ្លងផ្សេងៗទៀតដែរ។

### ត្រូវអនុវត្តន៍ជារៀងរាល់ថ្ងៃអំពីក្បួនអនាម័យដូចតទៅ

- លាងសំអាតដៃនឹងសាប៊ូ មុនពេលចាប់កាន់ចំណីអាហារ និងក្រោយពេលបន្ទោបង់ហើយ
- ត្រូវញាំុទឹកដាំពុះ
- ត្រូវញាំុចំណីអាហារដែលចំអិនឆ្អិនបានល្អ ហើយគ្របអោយជិតកុំអោយរុយរោម
- បន្លែ ឬផ្លែឈើ មុននឹងយកទៅញាំុត្រូវលាងទឹកអោយបានស្អាត
- ចាំបាច់ត្រូវពាក់ស្បែកជើងជានិច្ច
- អនាម័យខ្លួនប្រាណ
- ត្រូវប្រើបង្គន់អនាម័យ

| ប្រធានបទទី៤<br>រយៈពេល ១២០នាទី | **ការផ្តល់ថ្នាំទំលាក់ព្រូន Mebendazole/Albendazole ដល់ក្រុមគោលដៅនៅប្រទេសកម្ពុជា** |
| --- | --- |

### គោលដៅនៃការសិក្សា

នៅពេលរៀនចប់មេរៀននេះ សិក្ខាកាមនឹងៈ

- អាចយល់ដឹងពីស្ថានភាពបច្ចុប្បន្ននៃជំងឺព្រូននៅប្រទេសកម្ពុជា
- យល់ច្បាស់ពីក្រុមអាយុដែលងាយប្រឈមនឹងការចំលងជំងឺព្រូន
- យល់ច្បាស់ពីយុទ្ធនាការផ្តល់ថ្នាំទំលាក់ព្រូនដល់ក្រុមគោលដៅនៅប្រទេសកម្ពុជា
- អាចពន្យល់ពីយុទ្ធសាស្ត្រនៃការផ្តល់ថ្នាំទំលាក់ព្រូនដល់ក្រុមគោលដៅ

ដោយហេតុថាប្រទេសកម្ពុជាមានអាកាសធាតុក្តៅហើយសើមដែលបង្កភាពងាយស្រួលដល់ការចំលងជំងឺដង្កូវព្រូនដែលឆ្លងតាមដី ព្រមទាំងកង្វះអនាម័យនៅក្នុងទំលាប់ការងារប្រចាំជីវិតមួយចំនួនដូចជា ការប្រើប្រាស់លាមកមនុស្សមកធ្វើជាជីជាដើម ទើបប្រទេសកម្ពុជាយើងមានអត្រាជំងឺដង្កូវព្រូនដែលឆ្លងតាមដីខ្ពស់ និងកើតមាននៅពាស់ពេញប្រទេស។ នៅឆ្នាំ២០០២ អត្រាប្រេវ៉ាឡង់របស់ព្រូនចង្កឹះ (*A. lumbricoides*) មានពី 40%ដល់ 63% ហើយព្រូនរំពាត់សេះ (*T. trichiura*) មានពី 15 ដល់ 60% និងព្រូនទំពក់ (Hookworms) មានពី 20 ដល់ 83% ព្រមជាមួយ និងអត្រាអ្នកកើតព្រូនច្រើនមុខមានពី 60 ដល់ 70%។ មានប្រជាជនកម្ពុជាប្រហែលជាជាង៨លាននាក់ ដែលគេគិតថាកំពុងមានហានិភ័យប្រឈមនឹងការឆ្លងជំងឺដង្កូវព្រូនដែលឆ្លងតាមដី។ អ្នកដែលងាយប៉ះពាល់ជាងគេមាន កុមារវ័យជិតចូលរៀន កុមារក្នុងវ័យសិក្សា និងស្ត្រីក្នុងវ័យបន្តពូជ។ ផលប៉ះពាល់ទាំងឡាយដែលបណ្តាលមកពីជំងឺដង្កូវព្រូនដែលឆ្លងតាមដីរួមមាន កង្វះឈាម កង្វះអាហាររូបត្ថម្ភ និងមុខងារការបឺតស្រូបយកវីតាមីនអាមិនបានល្អ។

តាមការសិក្សាស្រាវជ្រាវថ្មីៗនេះ បានបង្ហាញអោយឃើញថាជំងឺព្រូនអង្គីលីស ឬព្រូនសសៃ (*S. stercoralis*) ក៏ជាបញ្ហាសុខភាពសារធារណដ៏ចំបងដែរនៅក្នុងប្រទេសកម្ពុជាយើង។ អង្គីលីសមិនត្រឹមតែជាដង្កូវព្រូនដែលអាចឆ្លងតាមដីបានប៉ុណ្ណោះទេតែវាក៏អាចធ្វើការចំលងដោយខ្លួនឯងនៅក្នុងខ្លួនមនុស្សដែរ (Autoinfection) នេះជាមូលហេតុនាំឱ្យឈានដល់ស្លាប់ជាពិសេសចំពោះអ្នកដែលមានប្រពន្ធ័ការពារខ្លួនខ្សោយ។ Ivermectin ជាថ្នាំមួយដែលយើងឃើញថាមានប្រសិទ្ធិភាពក្នុងការព្យាបាលជំងឺព្រូនអង្គីលីសឬព្រូនសសៃនេះ។

ឯកសារក្បួនណែនាំសំណូមពរអោយអនុវត្តន៍ការផ្តល់ថ្នាំទំលាក់ព្រូនដល់កុមារក្នុងវ័យសិក្សាទាំងអស់តាមរយៈកម្មវិធីទំលាក់ព្រូននៅតាមសាលារៀន និងកុមារត្រៀមចូលសាលារៀន (១២-៥៩ខែ) តាមរយៈសេវាចុះមូលដ្ឋានដោយមិនមានគិតពីអត្រាប្រេវ៉ាឡង់ ដោយហេតុថាការព្យាបាលជ្រើសរើសតែអ្នកដែលមានវត្តមានដង្កូវព្រូន គឺមិនអាចធ្វើទៅបានទេនៅក្នុងប្រទេសកម្ពុជា។ ចំណែកឯសមាជិកសហគមន៍ដទៃទៀត ជាពិសេសស្ត្រីក្នុងវ័យបន្តពូជក៏ត្រូវតែផ្តល់ថ្នាំ

ព្រូន ដោយផ្អែកលើអត្រាប្រេវ៉ាឡង់នៃដង្កូវព្រូនតាមរយៈការសិក្សាស្រាវជ្រាវ។

ក្នុងប្រទេសកម្ពុជា ថ្នាំមេបង់ដាស្សូល ឬអាល់បង់ដាស្សូល (Mebendazole/Albendazole) ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយតាមមូលដ្ឋានសាលាដែលមានកម្មវិធីទំលាក់ព្រូន និងតាមរយៈសេវាចុះតាមមូលដ្ឋានដោយរួមបញ្ចូលជាមួយកម្មវិធីចាក់ថ្នាំបង្ការ និងកម្មវិធីផ្តល់អាហាររូបត្ថម្ភ។ ថ្នាំទំលាក់ព្រូនមេបង់ដាស្សូល ឬអាល់បង់ដាស្សូល (Mebendazole/Albendazole) ត្រូវផ្គត់ផ្គង់តាមរយៈ មន្ទីរសុខាភិបាលខេត្ត ស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព។ ការផ្តល់ថ្នាំទំលាក់ព្រូនជាទូទៅនឹងត្រូវបានអនុវត្តន៍នៅសាលារៀន រោងចក្រ និងតាមរយៈសេវាចុះតាមមូលដ្ឋាន រួមសហការជាមួយនឹងមន្ទីរសុខាភិបាលខេត្ត មន្ទីរអប់រំយុវជន និងកីឡាខេត្ត មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ស្រុកប្រតិបត្តិ មណ្ឌលសុខភាព និងអង្គការក្រៅរដ្ឋាភិបាលនានា។ល។

## ក្រុមគោលដៅដែលត្រូវផ្តល់ថ្នាំទម្លាក់ដង្កូវព្រូន

1. **សិស្ស និងគ្រូ តាមសាលារៀនសាធារណៈ និងឯកជន**
   - កុមារមត្តេយ្យសិក្សា (ទាំង២ភេទ)
   - កុមារបឋមសិក្សា (ទាំង២ភេទ)
   - សិស្សមធ្យមសិក្សាបឋមភូមិ (ទាំង២ភេទ)
   - សិស្សមធ្យមសិក្សាទុតិយភូមិ (ទាំង២ភេទ)
   - គរុសិស្សនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ (ទាំង២ភេទ) ២៦ខេត្ត/រាជធានី ទូទាំងប្រទេស
2. **តាមសហគមន៍ទូទាំងរាជធានី ខេត្ត**
   - កុមារត្រៀមចូលសាលាអាយុចាប់ពី ១២-៥៩ ខែ (ទាំង២ភេទ)
   - កុមារសិស្សសាលាដែលពុំទាន់បានថ្នាំលេបក្នុងកំឡុងពេលផ្តល់ថ្នាំនៅសាលារៀន និងកុមារដែលពុំបានចូលរៀន ឬកុមារបោះបង់ចោលការសិក្សា (ទាំង២ភេទ)
   - ស្ត្រីស្ថិតក្នុងវ័យបន្តពូជអាយុចាប់ពី១៥-៤៩ឆ្នាំ (រួមបញ្ចូលទាំងស្ត្រីមានគភ៌ចាប់ពីត្រីមាសទី២ និងស្ត្រីក្រោយពេលសម្រាល)៖
     - ស្ត្រីនៅតាមសហគមន៍
     - ស្ត្រីធ្វើការនៅរោងចក្រ/សហគ្រាស

## យុទ្ធសាស្ត្រនៃការផ្តល់ថ្នាំទម្លាក់ដង្កូវព្រូន

- កុមារអាយុ ១២-៥៩ខែ អាចទទួលថ្នាំគ្រាប់ម៉េបង់ដាហ្សូល ឬអាល់បង់ដាស្សូល ១ដូស (លេបតែម្តង) ឱ្យបានទៀងទាត់យ៉ាងហោចណាស់១ដងក្នុង១ឆ្នាំ តាមរយៈ
  - មត្តេយ្យសាលារៀន ក្រោមការត្រួតពិនិត្យពីគ្រូប្រចាំថ្នាក់ និងនាយកសាលា ដោយមានការគាំទ្រពីបុគ្គលិកមណ្ឌលសុខភាព
  - ការផ្តល់សេវាសុខភាពចុះតាមមូលដ្ឋាន ដូចជាការចុះចាក់ថ្នាំបង្ការ ការផ្តល់ថ្នាំជីវជាតិអា និងការពិគ្រោះជំងឺតាមសេវាសុខភាពសាធារណៈ
- កុមារ/យុវវ័យក្នុងវ័យសិក្សាត្រូវតែបានទទួលថ្នាំគ្រាប់ម៉េបង់ដាហ្សូល ឬអាល់បង់ដាហ្សូល ១ដូស(លេបតែម្តង) ឱ្យបានទៀងទាត់យ៉ាងហោចណាស់១ដងក្នុង១ឆ្នាំ តាមរយៈ
  - សាលារៀន (សាធារណៈ និងឯកជន) ក្រោមការត្រួតពិនិត្យពីគ្រូប្រចាំថ្នាក់ និងនាយកសាលា ដោយមានការគាំទ្រពីបុគ្គលិកមណ្ឌលសុខភាព
  - ការផ្តល់សេវាសុខភាពចុះតាមមូលដ្ឋាន និងការពិគ្រោះជំងឺតាមសេវាសុខភាពសាធារណៈ
- ស្ត្រីស្ថិតក្នុងវ័យបន្តពូជអាយុ ១៥-៤៩ឆ្នាំ (ស្ត្រីមានគភ៌ចាប់ពីត្រីមាសទី២ និងស្ត្រីក្រោយពេលសម្រាល លើកលែងតែស្ត្រីមានគភ៌ចាប់នៅត្រីមាសដំបូង) អាចទទួលថ្នាំគ្រាប់ម៉េបង់ដាហ្សូល ឬអាល់បង់ដាស្សូ ១ដូស (លេបតែម្តង) ឱ្យបានទៀងទាត់យ៉ាងហោចណាស់១ដងក្នុង១ឆ្នាំ តាមរយៈ
  - ការផ្តល់សេវាសុខភាពតាមមូលដ្ឋាន ដូចជាការចុះចាក់ថ្នាំបង្ការ ការផ្តល់ថ្នាំជីវជាតិអា សេវាពន្យារកំណើត និងការពិគ្រោះជំងឺតាមសេវាសុខភាពសាធារណៈ
  - ការផ្តល់សេវាសុខភាពនៅតាមរោងចក្រ/សហគ្រាស

| ប្រធានបទទី៥<br>រយៈពេល ៩០នាទី | **គោលនយោបាយជាតិនៃការផ្តល់ថ្នាំទំលាក់ព្រូន Mebendazole/Albendazole ដល់ក្រុមគោលដៅ** |
|---|---|

**គោលដៅនៃការសិក្សា**

នៅពេលរៀនចប់មេរៀននេះ សិក្ខាកាមនឹងៈ

- អាចយល់ដឹងពីយុទ្ធសាស្ត្រក្នុងការពង្រឹងការផ្តល់ថ្នាំទំលាក់ព្រូនឲ្យមានប្រសិទ្ធិភាព
- យល់ច្បាស់ពីពីគោលនយោបាយជាតិនៃការផ្តល់ថ្នាំទំលាក់ព្រូន
- ចេះប្រើប្រាស់ថ្នាំទំលាក់ព្រូន Mebendazole/Albendazole ដល់ក្រុមគោលដៅ

## យុទ្ធសាស្ត្រក្នុងការពង្រឹងការផ្តល់ថ្នាំទំលាក់ព្រូនដល់ក្រុមគោលដៅអោយមានប្រសិទ្ធិភាពខ្ពស់

- ពង្រឹងចំណេះដឹង និងជំនាញស្តីពីការគ្រប់គ្រងកម្មវិធីដង្កូវព្រូនដល់មន្ត្រីសុខាភិបាលគ្រប់ជាន់ថ្នាក់ ចាប់ពីថ្នាក់ខេត្ត ស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព រួមទាំងដៃគូសហការជាពិសេសនាយកសាលានៃក្រសួងអប់រំយុវជន និងកីឡា និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បង្កើនចំណេះដឹង និងការចូលរួមពីការទទួលយកគ្រាប់ថ្នាំទំលាក់ព្រូនពីសហគមន៍តាមរយៈការអប់រំផ្សព្វផ្សាយ (អប់រំសុខភាព)
- បង្កើនការត្រួតពិនិត្យ និង ការចុះអភិបាលពីកម្មវិធីថ្នាក់ជាតិ ខេត្ត ស្រុកប្រតិបត្តិមណ្ឌលសុខភាព
- ពង្រឹងការគ្រប់គ្រង និងភស្តុភារនៃការស្នើសុំ និងចែកចាយគ្រាប់ថ្នាំព្រូនប្រភេទ Mebendazole/Albendazole
- ពង្រឹងការធ្វើរបាយការណ៍នៅគ្រប់ថ្នាក់

## គោលនយោបាយជាតិនៃការផ្តល់ថ្នាំទំលាក់ព្រូន Mebendazole/Albendazole ដល់ក្រុមគោលដៅ

- គ្រប់កុមារទាំងអស់ដែលបានមកមណ្ឌលសុខភាព មានអាយុចាប់ពី ១២ខែ ដល់ ៥៩ខែ ត្រូវតែផ្តល់ថ្នាំទំលាក់ព្រូន ១ដូស (លេបតែម្តង)
- គ្រប់កុមារដែលមានអាយុចាប់ពី ១២ខែ ដល់ ៥៩ខែ នៅក្នុងសហគមន៍ ត្រូវតែផ្តល់ថ្នាំទំលាក់ព្រូន១ដូស (លេបតែម្តង) រៀងរាល់ ខែឧសភា និង ខែវិច្ឆិកា តាមរយៈសេវាសុខាភិបាលចុះតាមមូលដ្ឋាន( ចាក់ថ្នាំបង្ការ ..........)

- សិស្សសាលារៀន (សាធារណៈ និងឯកជន) ទូទាំងប្រទេសត្រូវតែបានផ្តល់ថ្នាំទំលាក់ព្រូន ១ដូស(លេបតែម្តង) រៀងរាល់៦ខែម្តង គឺខែឧសភា និង ខែវិច្ឆិកា តាមរយៈគ្រូប្រចាំថ្នាក់ សហការជាមួយបុគ្គលិកមណ្ឌលសុខភាព
- ត្រូវផ្តល់ថ្នាំទំលាក់ព្រូន ១ដូស (លេបតែម្តង) ដល់គ្រប់ស្រ្តីមានគភ៌ចាប់ពី ៤ខែ ដល់ ៩ខែ និងស្រ្តីក្រោយសំរាលនៅមណ្ឌលសុខភាព និងតាមសេវាសុខភាពចុះតាមមូលដ្ឋាន
- ស្រ្តីស្ថិតក្នុងវ័យបន្តពូជអាយុ ១៥-៤៩ឆ្នាំ ត្រូវតែទទួលថ្នាំទំលាក់ព្រូន១ដូស (លេបតែម្តង) យ៉ាងហោចណាស់អោយបានម្តងក្នុង១ឆ្នាំ

## ប្រភេទ និងកម្រិតថ្នាំដែលត្រូវផ្តល់

- ថ្នាំគ្រាប់ម៉េបង់ដាហ្សូល៥០០មីលីក្រាម/អាល់បង់ដាហ្សូល៤០០មីលីក្រាម (Mebendazole 500mg/Albendazole 400mg) ជាថ្នាំដែលងាយស្រួលក្នុងការទំពាលេប និងគ្មានផ្តល់ផលវិបាកអ្វីឡើយ
- កម្រិតថ្នាំដែលត្រូវលេប
    - ទំពាលេប១គ្រាប់ តែម្តង (Oral Single Dose) ចំពោះបុគ្គលអាយុចាប់ពី ២ឆ្នាំឡើងទៅ
    - ទំពាលេបកន្លះគ្រាប់ (កាច់ថ្នាំជា២កំណាត់ ស្មើនឹង ២៥០mg ចំពោះថ្នាំ Mebendazole និងស្មើនឹង ២០០mg ចំពោះថ្នាំ Albendazole ) តែម្តង (Oral Single Dose) ចំពោះកុមារអាយុពី ១២ខែ ដល់ ២៣ខែ

## សកម្មភាពអនុវត្តន៍សំរាប់កម្មវិធីពេលចុះមូលដ្ឋាន

- បុគ្គលិកមណ្ឌលសុខភាពដែលចុះអនុវត្តន៍ការងារចាក់ថ្នាំបង្ការតាមភូមិ មុននឹងផ្តល់ថ្នាំព្រូនដល់កុមារ ត្រូវសួរព័ត៌មានជាមុនសិន។ បើកន្លងមកកុមារបានទទួលថ្នាំម៉េបង់ដាហ្សូល/អាល់បង់ដាហ្សូលម្តងរួចហើយក្នុងរយៈពេលតិចជាង៣ខែ កុមារនោះមិនត្រូវទទួលថ្នាំទៀតទេ
- មណ្ឌលសុខភាពត្រូវធ្វើសំណើសុំគ្រាប់ថ្នាំមេបង់ដាហ្សូល/អាល់បង់ដាហ្សូលសំរាប់សេវាចុះមូលដ្ឋានដោយគិតអាយុកុមារពី ១ឆ្នាំ ដល់ ៥ឆ្នាំ បូកបន្ថែមនឹងកុមារសិស្សសាលាបឋមសិក្សាទាំងអស់ និងមត្តេយ្យសាលាក្នុងមណ្ឌលសុខភាព

ប្រធានបទទី៦
រយៈពេល ១៥០នាទី

**តួនាទី និងភារៈកិច្ចរបស់វិស័យពាក់ព័ន្ធ ក្នុងការផ្តល់ថ្នាំទំលាក់ព្រូនដល់ក្រុមគោលដៅ**

**គោលដៅនៃការសិក្សា**

នៅពេលរៀនចប់មេរៀននេះ សិក្ខាកាមនឹង៖

- យល់ដឹងពីតួនាទី និងភារៈកិច្ចរបស់វិស័យពាក់ព័ន្ធ ក្នុងការផ្តល់ថ្នាំទំលាក់ព្រូនដល់ក្រុមគោលដៅ
- យល់ច្បាស់ពីកិច្ចសហការរបស់វិស័យពាក់ព័ន្ធក្នុងការផ្តល់ថ្នាំទំលាក់ព្រូនដល់ក្រុមគោលដៅ

## វិស័យសុខាភិបាល

### 1 កម្មវិធីជាតិទម្លាក់ដង្កូវព្រូន ត្រូវ

- ធ្វើផែនការអនុវត្តន៍កម្មវិធីផ្តល់ថ្នាំម៉េបង់ដាហ្សូល/អាល់បង់ដាហ្សូលដល់គ្រប់ក្រុមគោលដៅទាំងអស់
- សហការជាមួយ នាយកដ្ឋានសុខភាពសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា និងឃ្លាំងឱសថកណ្តាលនៃក្រសួងសុខាភិបាល ក្នុងការចែករំលែកព័ត៌មាន និងលើកគម្រោងផែនការតម្រូវការថ្នាំទម្លាក់ដង្កូវព្រូនប្រចាំឆ្នាំ សម្រាប់គ្រប់ក្រុមគោលដៅទាំងអស់
- ទទួល និងចែកចាយ សម្ភារទៅតាមតំបន់ ដូចជាសម្ភារអប់រំសុខភាពជាដើម
- រៀបចំផែនការបណ្តុះបណ្តាលពីយុទ្ធសាស្ត្រនៃកម្មវិធីដល់មន្ត្រីសុខាភិបាលនៅតាមតំបន់
- ពិនិត្យ តាមដាន និងវាយតម្លៃពីការអនុវត្តន៍កម្មវិធីផ្តល់ថ្នាំទម្លាក់ដង្កូវព្រូនទូទាំងប្រទេស ដោយសហការជាមួយនាយកដ្ឋានសុខភាពសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា។

### 2. ឃ្លាំងឱសថកណ្តាលរបស់ក្រសួងសុខាភិបាល ត្រូវ

- សហការជាមួយកម្មវិធីជាតិទម្លាក់ដង្កូវព្រូន ក្នុងការចែករំលែកព័ត៌មាន និងលើកគម្រោងផែនការតម្រូវការថ្នាំទម្លាក់ដង្កូវព្រូនប្រចាំឆ្នាំ សម្រាប់គ្រប់ក្រុមគោលដៅទាំងអស់
- ត្រូវធ្វើការផ្គត់ផ្គង់ថ្នាំទម្លាក់ដង្កូវព្រូន ទៅគ្រប់ស្រុកប្រតិបត្តិ ៤ដង ក្នុងមួយឆ្នាំ

3. **នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខាពេទ្យ និងគ្រឿងសំអាង ត្រូវ**

- សហការជាមួយកម្មវិធីជាតិទម្លាក់ដង្កូវព្រូន ដើម្បីធ្វើការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង ការចែកចាយឱសថ បរិក្ខារពេទ្យ សម្រាប់សេវាចុះមូលដ្ឋាន និងការគ្រប់គ្រងគ្រោះថ្នាក់ បណ្តាលមកពីហេតុការរំខានធ្ងន់ធ្ងរក្នុងកំឡុងពេលយុទ្ធនាការផ្តល់ថ្នាំទម្លាក់ដង្កូវព្រូន ដល់ក្រុមគោលដៅនៅប្រទេសកម្ពុជា
- រៀបចំឧបសម្ព័ន្ធសម្រាប់ធ្វើការណែនាំដល់មន្ទីរសុខាភិបាល ស្រុកប្រតិបត្តិ មណ្ឌលសុខភាពក្នុងការស្នើសុំការផ្តល់ថ្នាំទម្លាក់ដង្កូវព្រូន និងក្នុងការគ្រប់គ្រងគ្រោះថ្នាក់បណ្តាលមកពីហេតុការណ៍រំខានធ្ងន់ធ្ងរក្នុងកំឡុងពេលយុទ្ធនាការ
- ផ្តត់ផ្គង់ទម្រង់របាយការណ៍ស្តីពីប្រតិកម្មរំខានរបស់ឱសថជូនដល់កម្មវិធីជាតិទម្លាក់ដង្កូវព្រូនសម្រាប់យុទ្ធនាការ
- ចូលរួមសហការជាមួយកម្មវិធីជាតិទម្លាក់ដង្កូវព្រូនក្នុងការពិនិត្យ តាមដាន និងវាយតម្លៃលើគ្រោះថ្នាក់ដែលអាចកើតមានជាយថាហេតុបណ្តាលមកពីហេតុការរំខានធ្ងន់ធ្ងរក្នុងកំឡុងពេលយុទ្ធនាការ

4. **កម្មវិធីទម្លាក់ដង្កូវព្រូនថ្នាក់ខេត្ត និងស្រុកប្រតិបត្តិ ត្រូវ**

- សហការជាមួយមន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡា នៅតាមរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌនីមួយៗ ដើម្បីរៀបចំផែនការជាក់លាក់
- ផ្គត់ផ្គង់សម្ភារ (ថ្នាំម៉េបង់ដាហ្សូល/អាល់បង់ដាហ្សូល សម្ភារអប់រំសុខភាព) ទៅតាមមណ្ឌលសុខភាពឱ្យទាន់ពេលវេលា
- ប្រមូលទិន្នន័យប្រជាជនគោលដៅ (កុមារត្រៀមចូលសាលាអាយុ១២-៥៩ខែ កុមារមត្តេយ្យកុមារបឋមសិក្សា សិស្សមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ គរុសិស្ស គរុនិស្សិត លោកគ្រូ អ្នកគ្រូ ស្ត្រីស្ថិតក្នុងវ័យបន្តពូជ) ពីមណ្ឌលសុខភាពគ្របដណ្តប់ដោយស្រុកប្រតិបត្តិ
- ធ្វើសំណើសុំថ្នាំម៉េបង់ដាហ្សូល/អាល់បង់ដាហ្សូល តាមតម្រូវការចាំបាច់នៅក្នុងស្រុកប្រតិបត្តិទៅឃ្លាំងឱសថកណ្តាលរបស់ក្រសួងសុខាភិបាល រៀងរាល់ត្រីមាស
- ប្រមូលរបាយការណ៍ចែកចាយ ម៉េបង់ដាហ្សូល/អាល់បង់ដាហ្សូលប្រចាំខែពីមណ្ឌលសុខភាព
- បញ្ចូលទិន្នន័យចែកចាយឱសថប្រចាំខែបានពីមណ្ឌលសុខភាព ទៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាល(HIS)

- រៀបចំផែនការបណ្តុះបណ្តាលគ្រូបង្គោលដល់មន្ត្រីមណ្ឌលសុខភាព ដើម្បីបង្ហាត់បង្រៀនដល់លោកគ្រូ អ្នកគ្រូនៅតាមសាលារៀនឱ្យបានយល់ដឹងអំពីការផ្តល់ថ្នាំទម្លាក់ដង្កូវព្រូន ការអប់រំសុខភាពដល់សិស្ស និងសំណើសុំថ្នាំម៉េបង់ដាហ្សូលអាល់បង់ដាហ្សូល
- ពិនិត្យតាមដាន និងវាយតម្លៃពីសកម្មភាពផ្តល់ថ្នាំទម្លាក់ដង្កូវព្រូន ដល់ក្រុមគោលដៅនៅតាមសាលារៀន គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ រោងចក្រ/សហគ្រាស និងសហគមន៍

## 5. មណ្ឌលសុខភាព ត្រូវ

- ធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះសាលារៀន (សាធារណៈ និងឯកជន) ព្រមទាំងប្រជាជនគោលដៅសរុប(កុមារត្រៀមចូលសាលាអាយុ១២-៥៩ខែ កុមារមត្តេយ្យ កុមារបឋមសិក្សា សិស្សមធ្យម សិក្សាបឋមភូមិ និងទុតិយភូមិ គរុសិស្ស គរុនិស្សិត និងស្ត្រីស្ថិតក្នុងវ័យបន្តពូជ) ដែលស្ថិតក្នុងតំបន់គ្របដណ្តប់នៃមណ្ឌលសុខភាពរបស់ខ្លួនជាប្រចាំ
- ស្នើសុំថ្នាំម៉េបង់ដាហ្សូល/អាល់បង់ដាហ្សូល តាមតម្រូវការចាំបាច់នៅមណ្ឌលសុខភាពទៅការិយាល័យស្រុកប្រតិបត្តិ ជារៀងរាល់ខែ
- ដឹកនាំអនុវត្តន៍ការផ្តល់ថ្នាំទម្លាក់ដង្កូវព្រូន ដល់ក្រុមគោលដៅនៅសាលារៀន គ្រឹះស្ថានបណ្តុះបណ្តាលគ្រូទាំងអស់ រោងចក្រ/សហគ្រាស និងសហគមន៍ ឱ្យបានទៀងទាត់ និងមានប្រសិទ្ធភាព ដោយសហការជាមួយនាយកសាលារៀន គ្រឹះស្ថានសិក្សា និងអាជ្ញាធរមូលដ្ឋាន
- យកថ្នាំទម្លាក់ដង្កូវព្រូន ជូនគ្រប់សាលារៀន (សាធារណៈ និងឯកជន) គ្រឹះស្ថានបណ្តុះបណ្តាលគ្រូនិងរោងចក្រ/សហគ្រាស ឱ្យបាន ១ ឬ ២ខែ មុនពេលចុះយុទ្ធនាការទម្លាក់ដង្កូវព្រូន (ខែឧសភា និង ខែវិច្ឆិកា) នៃឆ្នាំនីមួយៗ
- ទាក់ទងទៅគ្រប់គ្រឹះស្ថានសិក្សាទាំងអស់ (សាធារណៈ និងឯកជន) និង រោងចក្រ/សហគ្រាស ដើម្បីសុំរបាយការណ៍នៃការផ្តល់ថ្នាំទម្លាក់ដង្កូវព្រូន មិនឱ្យលើសពី ១ខែ បន្ទាប់ពីយុទ្ធនាការទម្លាក់ដង្កូវព្រូនបានចប់
